ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 26 / 05 / 2016
ម៉ោង (Time/Heure): 15:05
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី សាធារណៈ

សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

ថ្ងៃ អង្គារ ទី ១៩ ខែ មេសា ឆ្នាំ ២០១៦

**សវនាការលើអង្គសេចក្តី - ថ្ងៃ ៣៩៩**

រៀបចំដោយ៖ **ជា ស៊ីវហ៊ាង** និង Roger PHILLIPS

| កំណត់ហេតុអ្នកចូលរួម |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Claudia FENZ , ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ កញ្ញា ជា ស៊ីវហ៊ាង, លោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Vincent De Wilde d' ESTMAEL, កញ្ញា សុង ឆវ័ន្ត, លោក Dale LYSAK |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSÉ |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marie GUIRAUD, លោក ឡោ ជុនធី, លោក សំ សុខគង់ ,លោក វ៉េន ពៅ , លោកស្រី ស៊ីន សុវ៉ន , លោក ហុង គឹមសួន, លោកស្រី ទី |

| |
|---|
| ស្រ៊ុនណា |
| ដើមបណ្ដឹង/សាក្សី/អ្នកជំនាញ៖ លោក ជុំ ម៉ី (2-TCCP-243), លោក ញ៉ែម អេន (2-TCW-919) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួ សុទ្ធាវី |
| ផ្សេងៗ៖ លោក កែវ រ៉ាត, កញ្ញា ស្រី ណាក់, លោក ឡូញ ង៉ែត, លោក នូ មនោរ័ត្ន, កញ្ញា Hannah KIM |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ | ចាប់ផ្ដើមម៉ោង៖ ០៩.០២ | បញ្ចប់ម៉ោង៖ ១៦.០៣ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.១៣ | បញ្ចប់ម៉ោង៖ ១០.៣៣ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៣៥ | បញ្ចប់ម៉ោង៖ ១៣.៣៣ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤៩ | បញ្ចប់ម៉ោង៖ ១៥.១៤ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ១៦ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០២ | ០៩.០៤ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.០៤ | ០៩.០៦ |
| ការកត់សម្គាល់ទៅលើការប្រើប្រាស់ឯកសារ E3/93.2 ដោយមេធាវីការពារក្ដី នួន ជា | សហព្រះរាជអាជ្ញា<br>មេធាវីការពារក្ដី នួន ជា<br>សហមេធាវីនាំមុខ<br>អង្គជំនុំជម្រះ | ០៩.០៧<br>០៩.១៦<br>០៩.២៤<br>០៩.២៨<br>១០.៣៤ | ០៩.១៦<br>០៩.២៤<br>០៩.២៥<br>០៩.៣០<br>១០.៣៧ |
| ការបន្តតាំងសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី (2-TCCP-243) | មេធាវីការពារក្ដី នួន ជា | ០៩.៣៧<br>១០.៣៨ | ១០.១៣<br>១១.១២ |
| ការស្ដាប់សារណាផ្ទាល់មាត់ទៅលើសំណើរបស់មេធាវីការពារក្ដី នួន ជា | អង្គជំនុំជម្រះ<br>មេធាវីការពារក្ដី នួន ជា | ១៣.៣៣<br>១៣.៣៥<br>១៣.៥៣ | ១៣.៣៥<br>១៣.៤២<br>១៣.៥៧ |

| | | | |
|---|---|---|---|
| | សហព្រះរាជអាជ្ញា | ១៣.៤២ | ១៣.៥១ |
| | សហមេធាវីនាំមុខ | ១៣.៥១ | ១៣.៥៣ |
| | មេធាវីការពារក្តី ខៀវ សំផន | ១៣.៥៣ | ១៣.៥៣ |
| | អង្គជំនុំជម្រះ | ១៥.១៤ | ១៥.១៧ |
| ការស្តាប់សារណាផ្ទាល់មាត់ទៅលើសំណើរបស់សហព្រះរាជអាជ្ញា | អង្គជំនុំជម្រះ | ១៣.៥៨ | ១៣.៥៨ |
| | សហព្រះរាជអាជ្ញា | ១៥.៥៨ | ១៤.០១ |
| | សហមេធាវីនាំមុខ | ១៤.០២ | ១៤.០២ |
| | មេធាវីការពារក្តី ខៀវ សំផន | ១៤.០៦ | ១៤.០៦ |
| ការតាំងសំណួរទៅកាន់សាក្សី ញ៉ែម អេន (2-TCW-919) | អង្គជំនុំជម្រះ | ១៤.៣១ | ១៤.៤២ |
| | មេធាវីការពារក្តី នួន ជា | ១៤.៤២ | ១៤.៥៩ |
| | | ១៥.១៧ | ១៦.០២ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**<u>សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឲ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**<u>ការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី (2-TCCP-243)</u>**

អង្គជំនុំជម្រះ និង មេធាវីការពារក្តី បានតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី (2-TCCP-243)។

**<u>ការកត់សម្គាល់លើការប្រើប្រាស់ឯកសារ E393.2 ដោយមេធាវីការពារក្តី នួន ជា</u>**

ភាគីបានធ្វើការកត់សម្គាល់ទៅលើការប្រើប្រាស់ឯកសារដោយមេធាវីការពារក្តី នួន ជា គឺឯកសារ E393.2 (ដែលត្រូវបានកែសម្រួល) ក្នុងអំឡុងពេលនៃការតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី នៅក្នុងថ្ងៃសវនាការមុនៗ។ ប្រធានអង្គជំនុំជម្រះបានឲ្យលោក Victor KOPPE ប្រគល់នូវសំណៅនៃឯកសារដែលមាននៅក្នុងបញ្ជីនោះ មកអង្គជំនុំជម្រះ ដើម្បីឲ្យភាគីដទៃទៀតទទួលបានឯកសារនោះដែរ។

អង្គជំនុំជម្រះបានសន្និដ្ឋានថា កាលបរិច្ឆេទ ដែលលោក Victor KOPPE បានយោងក្នុងការសួរដេញដោល ដើមបណ្តឹងរដ្ឋប្បវេណីកាលពីថ្ងៃសវនាការមុនៗនោះ គឺមិនស៊ីសង្វាក់គ្នាជាមួយនឹងកាលបរិច្ឆេទដែលមាន នៅក្នុងឯកសារ E393.2 នោះទេ។

សហព្រះរាជអាជ្ញាបានកត់សម្គាល់ថាមេធាវីការពារក្តី នួន ជា មិនបានដាក់ឯកសារដែលខ្លួនបានកែសម្រួលនោះនៅចំពោះមុខអង្គជំនុំជម្រះ ឬ ស្នើសុំឱ្យទទួលយកធ្វើជាភស្តុតាងនោះទេ។ បន្ទាប់មក សហព្រះរាជអាជ្ញាបានធ្វើការប្រៀបធៀបបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ ដែលមានក្នុងឯកសារ E393.2 ទៅនឹងបញ្ជីឈ្មោះក្នុងឯកសាររបស់សហព្រះរាជអាជ្ញា ដែលមានលេខឯកសារ E342 ហើយបានសន្និដ្ឋានថាមេធាវីការពារក្តី នួន ជា បានធ្វើការយោងមិនត្រឹមត្រូវទៅនឹងឯកសារ E393.2 ដូចជាកាលបរិច្ឆេទនៃការចាប់ខ្លួនអ្នកទោស ក្នុងការតាំងសំនួរទៅសាក្សី។ ដូច្នេះ សហព្រះរាជអាជ្ញា បានស្នើអង្គជំនុំជម្រះ កុំឱ្យមេធាវីការពារក្តីប្រើប្រាស់ព័ត៌មានមិនត្រឹមត្រូវតាមការសន្និដ្ឋានរបស់ខ្លួន ក្នុងការតាំងសំណួរព្រោះវាជាការបំភិតបំភ័យដើមបណ្តឹងរដ្ឋប្បវេណី។

ជាការឆ្លើយតបទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញា មេធាវីការពារក្តីលោក នួន ជា បានលើកឡើង ថាការចោទប្រកាន់យ៉ាងធ្ងន់ធ្ងរបែបនេះគួរត្រូវបានចោទដោយផ្ទាល់ទៅកាន់សហចៅក្រម ស៊ើបអង្កេតអន្តរជាតិ ហើយថាព័ត៌មានដែលខ្លួនបានប្រើប្រាស់ក្នុងការប្រឈមទៅនឹងសាក្សីគឺបានដកស្រង់ដោយផ្ទាល់ចេញពីឯកសារលេខ E393.2 ដែលឯកសារនោះត្រូវបានរៀបចំដោយការិយាល័យ សហចៅក្រមស៊ើបអង្កេត។ លើសពីនេះទៅទៀត មេធាវីការពារក្តីក៏បានកត់សម្គាល់ផងដែរថា សហព្រះរាជអាជ្ញាក៏បានយោងទៅលើបញ្ជីអ្នកទោសដែលខ្លួនបានកែតម្រូវផងដែរ អាស្រ័យហេតុនេះ មេធាវីការពារក្តីជំទាស់យ៉ាងខ្លាំងទៅនឹងការលើកឡើងដែលថា មេធាវីការពារក្តីបានប្រើប្រាស់ព័ត៌មាន មិនត្រូវត្រូវ ក្នុងការតាំងសំណួរទៅកាន់សាក្សីរូបនេះ។

សហមេធាវីនាំមុខក៏បានធ្វើការត្រួតពិនិត្យផងដែរលើកាលបរិច្ឆេទក្នុងបញ្ជីឈ្មោះអ្នកទោសក្នុងឯកសារ E393.2 ទៅនឹងកាលបរិច្ឆេទដែលយោងដោយមេធាវីការពារក្តី នួន ជា កាលពីថ្ងៃមុន ហើយកត់សម្គាល់ឃើញថាមានភាពខុសគ្នាជាច្រើន។

**<u>ការស្តាប់សារណាផ្ទាល់មាត់ទៅលើសំណើអនុលោមតាមវិធាន ៨៧(៤) របស់មេធាវីការពារក្តី នួន ជា</u>**

អង្គជំនុំជម្រះបានស្តាប់សារណាផ្ទាល់មាត់ពីភាគីនានាទាក់ទងនឹងសំណើរបស់មេធាវីការពារក្តី នួន ជា អនុលោមតាមវិធាន 87(4) នៃវិធានផ្ទៃក្នុង ដែលបានស្នើសុំឱ្យទទួលយកឯកសារចំនួនប្រាំបីពាក់ព័ន្ធ នឹងសាក្សី 2-TCW-919 រួមទាំងសៀវភៅដែលនិពន្ធដោយសាក្សីនេះផងដែរ ដើម្បីប្រើប្រាស់ក្នុងការ សួរដេញដោល។

មេធាវីការពារក្តីបានសង្ខេបនូវឯកសារទាំងប្រាំបី ដែលមាននៅក្នុងសំណើរបស់ខ្លួន ហើយបានសន្និដ្ឋាន

ថា ឯកសារទាំងនេះ និងសៀវភៅ គួរត្រូវបានទទួលយកដោយសារប្រយោជន៍យុត្តិធម៌។ មេធាវីការពារក្តី ក៏បានរម្លឹកផងដែរថា ខ្លួនមិនអាចរកសំណៅនៃសៀវភៅរបស់សាក្សីនេះបានទេ។

បើទោះបីសហព្រះរាជអាជ្ញាមិនយល់ស្របទៅនឹងតម្លៃនៃភស្តុតាងនៃឯកសារដែលបានស្នើសុំនោះក៏ដោយ សហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងឯកសារចំនួនប្រាំពីរ ព្រមទាំងសៀវភៅ ឱ្យទទួលយកជាភស្តុតាង អនុលោមតាមវិធាន ៨៧(៤) នោះទេ។ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹង អត្ថបទនៅក្នុងកាសែត Cambodia Daily ដែលបានចុះផ្សាយនៅថ្ងៃទី ០៦ ខែ មិនា ឆ្នាំ ២០១៥ ដោយបានលើកឡើងថា អត្ថបទនេះមិនពាក់ព័ន្ធក្នុងការបញ្ជាក់ពីភាពអាចជឿជាក់បានរបស់សាក្សីនេះទេ។

សហមេធាវីនាំមុខមិនបានធ្វើការជំទាស់នោះទេ លើកលែងតែឯកសារមួយ ក្នុងចំណោមឯកសារ ដែលបានស្នើសុំ។ សហមេធាវីនាំមុខបានលើកឡើងថា មិនមាភាគីណាមួយបានឃើញសៀវភៅនោះនៅ ឡើយទេ ហើយស្នើថាបញ្ហានេះអាចនឹងដោះស្រាយនៅពេលដែលភាគីបានទទួលសៀវភៅនោះ។ មេធាវីការពារក្តី ខៀវ សំផន មិនបានជំទាស់ទៅនឹងសំណើនេះទេ។

អង្គជំនុំជម្រះ បានចេញសេចក្តីសម្រេចទៅលើសំណើររបស់មេធាវីការពារក្តី នួន ជា ដែលបានស្នើសុំឱ្យ ទទួលយកឯកសារទាំងប្រាំបី ពាក់ព័ន្ធនឹងការសួរដេញដោលសាក្សី 2-TCW-919។ អង្គជំនុំជម្រះបាន ទទួលយកឯកសារចំនួន ៧ ហើយច្រានចោលសំណើឱ្យទទួលយកអត្ថបទកាសែត Cambodia Daily ។ អង្គជំនុំជម្រះបានរម្លឹកភាគីថា អង្គជំនុំជម្រះនិងសេចក្តីសម្រេចដោយឡែក ពាក់ព័ន្ធនឹងការទទួលយក សៀវភៅដែលបាននិពន្ធដោយ ញ៉ែម អេន។

**<u>ការស្តាប់សារណាផ្ទាល់មាត់ទៅលើ សំណើររបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍ របស់មេធាវីជាតិការពារក្តីឱ្យ ខៀវ សំផន ដែលអាចនឹងកើតមានឡើង</u>**

អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សារណាផ្ទាល់មាត់ពីភាគីនានាទាក់ទងនឹងសំណើរបស់សហព្រះរាជ អាជ្ញា ពាក់ព័ន្ធនឹងការតំណាងសាក្សីពីមុនដោយមេធាវីជាតិការពារក្តីឱ្យ លោក ខៀវ សំផន (មេធាវី គង់ សំអុន) ក្នុងសំណុំរឿង ០០១ និងទំនាស់ប្រយោជន៍ដែលអាចនឹងកើតមានឡើងរវាងគាត់ និង លោក ខៀវ សំផន។

សហព្រះរាជអាជ្ញា បានលើកឡើងថា គួរទទួលបានការលះបង់ និង ការព្រមព្រៀងមួយពីលោក ខៀវ សំផន ពាក់ព័ន្ធនឹងសិទ្ធិរបស់គាត់ក្នុងការលើកឡើងពីបញ្ហានៃទំនាស់ប្រយោជន៍ដែលអាចនឹងកើតមាននេះ នៅក្នុងបណ្តឹងសារទុក្ខ។ សហព្រះរាជអាជ្ញា បានបញ្ជាក់បន្ថែមថា លោក គង់ សំអុន មិនគួរសួរដេញដោលសាក្សីពាក់ព័ន្ធនេះទេ។

សហមេធាវីនាំមុខ មិនឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាទេ។ មេធាវីការពារក្តី នួន ជា

បានលើកឡើងថា នៅក្នុងកាលៈទេសៈនេះ មិនមានទំនាស់ផលប្រយោជន៍នោះទេ។
មេធាវីអន្តរជាតិការពារក្តីឱ្យលោក ខៀវ សំផន បានយល់ស្របទៅនឹងដំណោះស្រាយរបស់អង្គជំនុំជម្រះដែលថាលោក គង់ សំអុន មិនគួរតាំងសំណួរទៅកាន់សាក្សី ហើយថានេះជាវិធីសមស្រប។ ចៅក្រម FENZ បានសួរទៅកាន់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ថាតើលោក ខៀវ សំផន យល់ព្រមដាក់នៅក្នុងកំណត់ត្រាអំពីការលះបង់សិទ្ធិរបស់គាត់ ក្នុងការលើកឡើងអំពីបញ្ហានៃទំនាស់ផលប្រយោជន៍ដែលអាចនឹងកើតឡើងមកពីការតំណាងពីមុនដោយមេធាវីរបស់គាត់ នៅក្នុងបណ្តឹងសារទុក្ខដែរឬទេ។ ជាការឆ្លើយតប មេធាវីការពារក្តីលោក ខៀវ សំផន បានលើកឡើងថា វាមានការលំបាកខ្លាំងណាស់ក្នុងការពិភាក្សាអំពីសំណើនេះជាមួយលោក ខៀវ សំផន ក្នុងពេលនេះដោយសារគាត់មានបញ្ហាក្នុងការស្តាប់ ហើយស្នើសុំអង្គជំនុំជម្រះផ្តល់ពេលវេលា ៥ នាទី ដើម្បីពិភាក្សាបញ្ហានេះជាមួយគាត់។
អង្គជំនុំជម្រះ បានពន្យារការសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍ដែលអាចកើតមាន ទាក់ទងនឹងលោកមេធាវី គង់ សំអុន។

**<u>ការតាំងសំណួរទៅកាន់សាក្សី ញ៉ែម អេន</u>** <u>(2-TCW-919)</u>
អង្គជំនុំជម្រះ និង មេធាវីការពារក្តី នួន ជា បានតាំងសំណួរទៅកាន់សាក្សី 2-TCW-919។

New E3s

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/9838 | D108/3/15.1 | 00162872-00162874; 00162872-00162874; 00162872-00162874 | Photographs of NHEM En | P | - | 00162874 | - |

Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/7468 | D288/4.57.1 | 00360437-00360537; 00360157-00360289; 00360290-00360436 | Transcript of Proceedings - "Duch" Trial - 04 August 2009 | P | - | - | - |
| E3/9214 | E305/13.23.66 | 00993310-00993366 | New DC-Cam Photographs of S-21 Prisoners | P | - | - | - |
| E3/2186 | D108/26.152 | 00086993-00086995; 00181716-00181717; - | Annex 152: S-21 Prisoner List containing names of prisoners from the Public Works Section | P | - | - | - |
| E3/5163 | D108/30 | 00176400-00176403; 00176404-00176406; 00176407-00176409 | Written Record of Interview Civil Party CHUM Mey | P | 00176401 | 00176405 | 00176408 |
| E3/5769 | D86/19 | 00166588-00166599; 00166561-00166570; 00166571-00166580 | Written Record of Confrontation on 29-02-2008 | P | 00166590 | 00166563 | 00166573 |
| E3/5765 | D86/16 | 00181328-00181346; 00197998-00198008; 00181347-00181356 | Report of Crime Scene Reenactment at TUOL Sleng on 27 February 2008 | P | - | - | - |
| E3/7451 | D288/4.40.1 | 00347916-00347995; 00346456-00346552; 00346553-00346655 | Transcript of Proceedings - "Duch" Trial - 30 June 2009 | P | - | - | - |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/5794 | D288/4.17.1 | 00325768-00325847; 00325546-00325651; 00325652-00325767 | [Corrected 1] Transcript of Proceedings - "Duch" Trial - 28 April 2009 | P | - | - | - |
| E3/2117 | D108/50/1.4.20 | 00192933-00193063; 00081277-00081488; 00762103-00762110 | Book by HUY Vannak entitled:"The Khmer Rouge Division 703: From Victory to Self-destruction" | P | 00192958-00192959 | 00081318 | - |

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E393.2 | | 01222328-01222936 | Annex 2: OCIJ S-21 Prisoners List 31 March 2016 | C | | | |
| E3/42 | D167 | 00327200-00327211; 00327212-00327221; 00327222-00327230 | Written Record of Interview of witness SUONG Sikoeun by CIJ on 06 May 2009 | P | - | - | - |
| E3/68 | D108/3/15 | 00162833-00162851; 00401814-00401833; 00195653-00195672 | Written Record of Interview of NHEM En | P | 00162837 | 00401819 | 00195658 |

**ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៥)
- សេចក្ដីសម្រេចផ្ទាល់មាត់ទទួលយកឯកសារចំនួន ៧ ក្នុងចំណោមឯកសារដែលបានស្នើឱ្យទទួលយក ដោយមេធាវីការពារក្ដី នួន ជា។ (១៥.១៥)
- ពន្យាពេលសម្រេចទៅលើសំណើរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍ដែលអាចកើតឡើង របស់មេធាវី គង់ សំអុន ដែលជាមេធាវីជាតិការពារក្ដីឱ្យលោក ខៀវ សំផន។ (១៥.១៦)
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.០០ ព្រឹក នៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៦។ (១៦.០២)

**កាលវេលាសវនាការបន្ត**

សវនាការនឹងបន្តទៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៦ ចាប់ផ្ដើមពីម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦

ក្រឡាបញ្ជី ក្រឡាបញ្ជី

ជា ស៊ីវ[illegible] [illegible]er PHILLIPS